# ភាពងាយរងគ្រោះ
# នៃការប្រែប្រួលអាកាសធាតុរបស់សហគមន៍នេសាទ

ការប្រឈម + ភាពងាយរងផលប៉ះពាល់ + សមត្ថភាពបន្សាំ = ភាពងាយរងគ្រោះ

## ព័ត៌មានអំពីការប្រឈម

### សីតុណ្ហភាព

សហគមន៍នេសាទចំនួន ៥នៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា




**ការកើនឡើងសីតុណ្ហភាពមធ្យមប្រចាំឆ្នាំក្នុងកម្រិត** — **០,៤៥ អង្សា** ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២៤។

**ការព្យាករណ៍ពីកំណើនសីតុណ្ហភាពមធ្យមប្រចាំឆ្នាំនៅតំបន់ឆ្នេរ**
- **០,៧ ដល់ ២,៧ អង្សា** ត្រឹមទសវត្សរ៍ឆ្នាំ២០៦០
- **១,៤ ដល់ ៤,៣ អង្សា** ត្រឹមទសវត្សរ៍ឆ្នាំ២០៩០

**នៅតំបន់ឆ្នេរ សមុទ្រដែលធំល្វឹងល្វើយ ងាយប្រឈមបំផុតទៅនឹងការកើនឡើងនៃសីតុណ្ហភាព។**

### ព្រឹត្តិការណ៍ធម្មជាតិធ្ងន់ធ្ងរ

- ព្រៃកោងកាង និងវាលស្មៅសមុទ្រ គឺជាពិសេសងាយរងគ្រោះពីការខូចខាតដោយខ្យល់ព្យុះ។

### កម្ពស់ទឹកភ្លៀង

**↓ 100 មីលីម៉ែត្រ**
កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំថយចុះប្រមាណពីឆ្នាំ២០០០ ដល់ឆ្នាំ២០២៤។

- ការព្យាករណ៍នៅតំបន់ឆ្នេរបង្ហាញពីការថយចុះតិចតួចនៃកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំនាពេលអនាគតដ៏ខ្លីខាងមុខនេះ ជាមួយនឹងការកើនឡើងកម្ពស់ទឹកភ្លៀងខ្លាំងបំផុតសម្រាប់រយៈពេលមួយថ្ងៃ ខណៈពេលដែលកម្ពស់ទឹកសរុបភ្លៀងរយៈពេលប្រាំថ្ងៃនឹងថយចុះ។ នៅតំបន់ឆ្នេរ ដីកសិកម្មងាយនឹងប្រឈមជាពិសេស ដោយសារតែបម្រែបម្រួលកម្ពស់ទឹកភ្លៀង។

### ការកើនឡើងកម្ពស់ទឹកសមុទ្រ

**↑ ៦០ សង់ទីម៉ែត្រ**

- ហានិភ័យខ្ពស់នៃការកើនឡើងកម្ពស់ទឹកសមុទ្រ ដូចធ្លាប់កើតមានកន្លងមក (រវាងឆ្នាំ១៩៩៣ និងឆ្នាំ២០១៥)។
- ហានិភ័យខ្ពស់នៃការកើនឡើងកម្ពស់ទឹកសមុទ្រនាពេលអនាគត ដោយការព្យាករណ៍ប៉ាន់ស្មានថា ត្រឹមទសវត្សរ៍ឆ្នាំ២០៩០ កម្ពស់ទឹកសមុទ្រក្នុងតំបន់នឹងកើនឡើងប្រមាណ៦០សង់ទីម៉ែត្រលើសពីកម្ពស់ទឹកសមុទ្រដើមគ្រា ដែលកំណត់កាលពីឆ្នាំ១៩៨៦-២០០៥។
- អាងទឹកសាប និងដែនជម្រកតាមតំបន់ឆ្នេរនានា គឺងាយប្រឈមបំផុតទៅនឹងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ។


គាំទ្រផលិតដោយ៖ Landesa

ការអនុវត្តគម្រោង ជីវភាពតំបន់ឆ្នេរ និងព្រៃកោងកាង

របាយការណ៍ពេញលេញជាភាសាអង់គ្លេស
របាយការណ៍ពេញលេញជាភាសាខ្មែរ

# ព័ត៌មានអំពីភាពខាយរងផលប៉ះពាល់

## ជីវភាពរស់នៅរបស់សហគមន៍នេសាទ

- ការនេសាទ ការកែច្នៃត្រី កសិកម្ម និងការចិញ្ចឹមសត្វ គឺជាមុខរបរចម្បងរបស់បុរស និងស្ត្រី។

បុរស ៥០% | ស្ត្រី ៣៤%

## កសិកម្ម

- គេរំពឹងថា ការប្រែប្រួលអាកាសធាតុ នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើផលិតកម្មដំណាំ ដោយសារតែការកើនឡើងនៃការជ្រាបចូលជាតិប្រៃមកលើផ្ទៃដី ការកើនឡើងនៃអត្រារំហួតទឹក និងការកើនឡើងនៃភាពញឹកញាប់ និងភាពខ្លាំងក្លានៃទឹកជំនន់ និងគ្រោះរាំងស្ងួត។
- សកម្មភាពកសិកម្មរបស់សមាជិកសហគមន៍នេសាទ ងាយរងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ដែលអាចគំរាមកំហែងដល់ មុខរបរចម្បងរបស់បុរសប្រមាណ ១៤% និងស្ត្រីប្រមាណ ៥% ក្នុងសហគមន៍នេសាទ។

បុរស ១៤% | ស្ត្រី ៥%

## ព្រៃឈើ

- ភាពប្រែប្រួលនៃអាកាសធាតុអាចបង្កផលប៉ះពាល់អវិជ្ជមានលើសមាសភាពនិងផលិតភាពនៃព្រៃកោងកាងដែលប៉ះពាល់អវិជ្ជមានដល់ ការប្រមូលផលិតផលព្រៃឈើនិងអនុផលព្រៃឈើរបស់សហគមន៍សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬក្នុងគ្រួសារ។

## ការនេសាទ

**១២% ដល់ ៩៨%**

- ផលចាប់សក្តានុពលសរុបនឹងថយចុះពី ១២% ដល់ ៩៨% ត្រឹមទសវត្សរ៍ឆ្នាំ២០៩០ ដោយសារការកើនឡើងនៃសីតុណ្ហភាពលើផ្ទៃសមុទ្រ និងជាតិអាស៊ីតក្នុងទឹកសមុទ្រ។
- ការនេសាទ និងការកែច្នៃត្រី ងាយរងផលប៉ះពាល់ខ្ពស់ដោយសារការប្រែប្រួលអាកាសធាតុ ដែលអាចបង្កហានិភ័យដល់មុខរបរចម្បងរបស់បុរស និងស្ត្រី។

បុរស ៣២% | ស្ត្រី ២០%

- ជាមធ្យម ផលប៉ះពាល់ទាក់ទងនឹងអាកាសធាតុអាចប៉ះពាល់អវិជ្ជមានដល់ប្រាក់ចំណូលផ្ទាល់ខ្លួនរបស់អ្នកនេសាទជាបុរស ៥៧% និងអ្នកនេសាទជាស្ត្រី ៦០%។

បុរស ៥៧% | ស្ត្រី ៦០%

## ការចិញ្ចឹមសត្វ

- ការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យការផ្ទុះឡើងនៃសមាសភាគចង្រៃកាន់តែងាយកើតឡើង ព្រមទាំងនាំឱ្យមានការបាត់បង់សត្វចិញ្ចឹមជាលក្ខណៈគ្រួសារ ដោយសារគ្រោះមហន្តរាយទាក់ទងនឹអាកាសធាតុ។
- សកម្មភាពចិញ្ចឹមសត្វរបស់សមាជិកសហគមន៍នេសាទ ងាយរងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ដែលអាចគំរាមកំហែងដល់មុខរបរចម្បងរបស់បុរស ប្រមាណ ៤% និងស្ត្រីប្រមាណ ៨% ក្នុងសហគមន៍នេសាទ។

បុរស ៤% | ស្ត្រី ៨%

# ព័ត៌មានអំពីសមត្ថភាពបន្ស៊ាំ

- បញ្ហាប្រឈម ដែលរារាំងដល់ការធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិតរបស់សមាជិកសហគមន៍នេសាទ សម្រាប់ជាយន្តការបន្ស៊ាំ៖
  - ទស្សនៈយល់ឃើញផ្សេងៗគ្នាក្នុងចំណោមសមាជិកនៃគណៈកម្មការសហគមន៍នេសាទ និងការចូលរួមរបស់សហគមន៍មានកម្រិតទាប ដែលនាំឱ្យមានដំណើរការសម្រេចចិត្តមានភាពយឺតយ៉ាវ។
  - ភាពចាំបាច់ក្នុងការបង្កើនចំណេះដឹងនិងជំនាញបច្ចេកទេសពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រមែប្រមូលមូលនិធិ និងដោះស្រាយបញ្ហាបរិស្ថាន ដូចជា ការរំលោភបំពានព្រៃកោងកាង និងការបញ្ចេញកាកសំណល់ ជាដើម។

# ព័ត៌មានអំពីភាពខាយរងគ្រោះ

- ដោយសារតែការប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុភាពងាយរងផលប៉ះពាល់ក្នុងវិស័យសំខាន់ៗ និងបញ្ហាប្រឈមដែលរារាំង ដល់ការលើកកម្ពស់ជម្រើសជីវភាពរស់នៅផ្សេងៗ ជីវភាពរស់នៅរបស់សហគមន៍នេសាទមានភាពងាយរងគ្រោះខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុ ស្របគ្នាជាមួយនឹងការរកឃើញរបស់ប្រទេសកម្ពុជា និងតំបន់ឆ្នេរនៅកម្ពុជា។

គាំទ្រផលិតដោយ៖ Landesa

ការអនុវត្តគម្រោង ជីវភាពតំបន់ឆ្នេរ និងព្រៃកោងកាង

Building Community Voices | FACT | PDP Center | ADIC Analyzing Development Issues Centre

របាយការណ៍ពេញលេញជាភាសាអង់គ្លេស

របាយការណ៍ពេញលេញជាភាសាខ្មែរ